# អរិយធម៌ទីវ៉ាណាគូ (Tiwanaku Civilization)

អរិយធម៌ទីវ៉ាណាគូ (Tiwanaku) ឬ តាហ៊ូណាកូ (Tiahuanaco) គឺជាអរិយធម៌ចំណាស់មួយក្នុងចំណោមអរិយធម៌ចំណាស់ទាំងបី ក្នុងតំបន់ជ្រលងភ្នំអេនឌៀន (Andean Civilization ) ដែលរួមមាន អរិយធម៌ឆាវិន, អរិយធម៌វ៉ារី និងអរិយធម៌ទីវ៉ាណាគូ។[១] អរិយធម៌នេះមានទីតាំងស្ថិតនៅក្បែរទន្លេ ទីទីកាកា ( Titicaca )សព្វថ្ងៃស្ថិតនៅក្នុងខេត្ត អ៊ីងហ្គាវី (Ingavi) ដែលមានចម្ងាយប្រមាណជាង៧០គីឡូពីរាជធានី ឡាប៉ាស (La Paz) នៃប្រទេស បូលីវី ហើយអរិយធម៌នេះមានរាជធានីក៏ហៅថា ទីវ៉ាណាគូដែរ។ តាមរយៈការស្រាវជ្រាវលើអរិយធម៌ទីវ៉ាណាគូបានរកឃើញទីតាំងស្ថានីយបុរាណៗជាច្រើន ដែលស្ថិតនៅតាមប្រទេសជាច្រើននៅក្នុងតំបន់ទ្វីបអាមេរិកខាងត្បូង ដែលរួមមានផ្នែកខាងនៃប្រទេសប៉េរូ, បូលីវី និងប្រទេសឈីលីជាដើម ( រូបលេខ១)។[២]

ទីក្រុងទីវ៉ាណាគូត្រូវបានរកឃើញដោយពួកអេស្ប៉ាញ នៅពេលគ្រប់គ្រងបណ្តាប្រទេសក្នុងតំបន់ទ្វីបអាមេរិកនៅអំឡុងស.វ.ទី១៦ (រូបលេខ២)។[៣] ទីក្រុងនេះ មានកំពែងដី និងគូរទឹកដែលបង្ហាញពីទម្រង់សិល្បៈសំណង់របស់អរិយធម៌ ដែលនៅតាមជ្រលងភ្នំអេនឌៀន (Andean Civilization) ដែលរួមមានសំណង់ប្រាសាទ និងរចនាសម្ព័ន្ធសាធារណៈផ្សេងៗ។[៤] បើសង្កេតមើលតាមប្លង់នៃការរៀបចំក្រុងទីវ៉ាណាគូ គឺជាការរៀបចំជាបណ្តុំនៃសំណង់សាសនា (Complex monuments) ដែលសំណង់គោលនោះ គឺជាប្រាសាទពីរ៉ាមីត Akapana, ប្រាសាទ Kalasasaya និងប្រាសាទ Pumapumku សម្រាប់គោរពដល់ Staff God ដែលប្រជាជននៅក្នុងអរិយធម៌នេះគោរព (រូបលេខ៣)។ ចំពោះ អត្ថន័យ Staff God គឺមានន័យជាច្រើនខុសៗគ្នាដែលអាស្រ័យលើតំបន់ប្រជាជនដែលគោរពលើអទិទេពនេះ ក្នុងអរិយធម៌ទីវ៉ាណាគូបុរាណ។ សំណង់ប្រាសាទពីរ៉ាមីត Akapana កសាងពីថ្មទំហំធំៗតំរៀបលើគ្នា ដែលមានកំពស់ប្រមាណជាង១៩ម៉ែត្រ។ ប្រាសាទសំខាន់មួយទៀត គឺប្រាសាទ Kalasasaya ដែលកសាងជារាង

---

[១] https://www.britannica.com/topic/pre-Columbian-civilizations/Andean-civilization

[២] Erik J. Marsh, 2012,P.169.

[៣] https://www.britannica.com/place/Tiwanaku

[៤] *Ibid*

ចតុកោណ និងមានសំណង់ថ្មមួយដែលហៅថា Gate of the Sun ដែលនៅចំកណ្តាលនៃ Gate of the sun នោះ មានរូប Staff gods ដែលមនុស្សក្នុងអរិយធម៌នេះ ជឿថាសំណង់ Gate of the sun ជាសំណង់ដ៏សំខាន់នៅក្នុងអរិយធម៌ទីវ៉ាណាគូនេះ(រូបលេខ២)។[៥] សំណង់សិល្បៈស្ថាបត្យកម្មបានបង្ហាញថា ទីក្រុងទីវ៉ាណាគូ គឺជាទីក្រុងបណ្តុំនៃសំណង់សាសនាដែលធំជាងគេនៅក្នុងអរិយធម៌ផ្សេងទៀត នៃបណ្តាអរិយធម៌អេនឌៀន (Andean Civilization)។ អ្នកស្រាវជ្រាវក៏បានបង្ហាញថា មនុស្សក្នុងអរិយធម៌នេះមានការបិនប្រសព្វ និងមានបច្ចេកទេសខ្ពស់ក្នុងការសាងសង់ដែលស្របទៅនឹងមជ្ឈដ្ឋានក្នុងតំបន់។ លើសពីនេះក៏មានជំនាញក្នុងការផលិតវត្ថុសិល្បៈ តាមទម្រង់ផ្សេងៗដែលបានរកឃើញពីកន្លែងជាច្រើននៃអរិយធម៌នេះរួមមាន គ្រឿងស្មូនដី គ្រឿងអលង្ការ និងរូបចម្លាក់ដី ថ្មនិងលោហៈធាតុ (រូបលេខ៥-៨ )។ សិល្បៈ និងសំណង់ស្ថាបត្យកម្មទាំងនោះ គឺជាសិល្បៈដែលមានទម្រង់ប្លែក តែមានបច្ចេកទេសខ្ពស់ ដែលភាគច្រើឆ្លាក់ចេញពីថ្មភ្នំ និងរូបគំនូរលើកុលាលភាជន៍ (រូបលេខ៩-១២)។ ជាពិសេសរូបចម្លាក់ Staff Gods ដែលឆ្លាក់ពីថ្មជាដើម។

អ្នកស្រាវជ្រាវពុំដឹងអំពីមូលហេតុច្បាស់លាស់ នៃការដួលរលំអរិយធម៌ទីវ៉ាណាគូនេះនៅឡើយទេ ប៉ុន្តែអាចប្រហែលមកពីការប្រែប្រួលអាកាសធាតុក្នុងតំបន់ និងមានការឈ្លានពីអរិយធម៌ដទៃទៀត និងមានកត្តាផ្សេងៗដែលធ្វើឱ្យអរិយធម៌ដ៏រុងរឿងមួយនេះបានដួលរលំ។[៦]

ជារួមអរិយធម៌ទីវ៉ាណាគូ គឺជាអរិយធម៌ដ៏សំខាន់មួយនៅក្នុងការសិក្សានៃអរិយធម៌មុនអ៊ីនកា ជាពិសេសទីក្រុងរបស់អរិយធម៌នេះ ដែលជាបណ្តុំនៃសំណង់សាសនាដ៏ល្បីល្បាញនៅក្នុងតំបន់អរិយធម៌នៅតាមជ្រលងភ្នំអេនឌៀន។ ម្យ៉ាងទៀតអរិយធម៌នេះ ក៏ជាអាណាចក្រដ៏រុងរឿងណាស់ដែរ ក្នុងចំណោមបណ្តាអរិយធម៌មុនអ៊ីនកាដ៏ទៃទៀត ដោយអរិយធម៌ទីវ៉ាណាគូនេះមានការរីកចម្រើនខ្លាំងនៅអំឡុងស.វ.ទី៦នៃគ.ស. និងត្រូវបានដួលរលំនៅអំឡុងស.វ.ទី១១នៃគ.ស. ពោលគឺមានរយៈពេលប្រមាណ ៥០០ឆ្នាំ។[៧]

---

[៥] Ibid

[៦] https://www.uwlax.edu/globalassets/offices-services/urc/jur-online/pdf/2006/tenpas.pdf

[៧] Tiwanaku: Spiritual and Political Centre of the Tiwanaku Culture - UNESCO World Heritage Centre

អត្ថបទដោយ៖ អេង តុលា




រូបលេខ១៖ ផែនទីនៃអរិយធម៌ទីវ៉ាណាគូ

ប្រភព៖ https://www.khanacademy.org/humanities/art-americas/south-america-early/xf20f462f:tiwanaku/a/semi-subterranean-court-at-the-site-of-tiwanaku

KHMER CIVILIZATION



រូបលេខ២៖ ទីក្រុងទីវ៉ាណាគូ

ប្រភព៖ https://fineartamerica.com/featured/1-south-america-bolivia-tiwanaku-kymri-wilt.html?product=poster




រូបលេខ៣៖ ផែនទីទីក្រុងទីវ៉ាណាគូ

ប្រភព៖ https://fineartamerica.com/featured/1-south-america-bolivia-tiwanaku-kymri-wilt.html?product=poster



រូបលេខ២៤៖ Gate of the sun រូមទឹង staff god នៅកណ្តាល

ប្រភព៖ https://fineartamerica.com/featured/1-south-america-bolivia-tiwanaku-kymri-wilt.html?product=poster



រូបលេខ២៥៖ ប្រាសាទ kalasasaya

ប្រភព៖ https://fineartamerica.com/featured/1-south-america-bolivia-tiwanaku-kymri-wilt.html?product=poster

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៦៖ រូបចម្លាក់ថ្មក្នុងសិល្បៈទីវ៉ាណាគូ
ប្រភព៖ https://fineartamerica.com/featured/1-south-america-bolivia-tiwanaku-kymri-wilt.html?product=poster





រូបលេខ២៧-៨ ៖ រូបចម្លាក់ក្នុងសិល្បៈទីវ៉ាណាគូ
ប្រភព៖ https://www.artic.edu/artists/43218/tiwanaku
https://fineartamerica.com/featured/1-south-america-bolivia-tiwanaku-kymri-wilt.html?product=poster

អត្ថបទដោយ៖ អេង តុលា





រូបលេខ៩-១០ ៖ រូបចម្លាក់ក្នុងសិល្បៈទីវ៉ាណាគូ

ប្រភព៖ https://www.artic.edu/artists/43218/tiwanaku

អរិយធម៌ខ្មែរ
KHMER CIVILIZATION





រូបលេខ១១-១២ ៖ កុលាលភាជន៍រូបសត្វ ដោយមានរូបគំនូរ
ប្រភព៖
https://www.artic.edu/artists/43218/tiwanaku